

## ៨. ការគ្រប់គ្រងទឹក

បើស្រែមានលទ្ធភាពអាចបញ្ចេញបញ្ចូលទឹកបាន ត្រូវលៃយ៉ាងណាឱ្យនៅក្នុងស្រែត្រូវមានទឹកតិចៗ ជៀសវាងទឹកដក់ច្រើន នោះជាការប្រសើរ ។

## ៩. ការដាក់ជី

ជាការល្អគួរប្រើជីធម្មជាតិឱ្យបានច្រើន ជាពិសេសជីកំប៉ុស្ត ប្រហែល ៣-៤ តោន ក្នុង ១ហិកតា។ បើអាចដាំជីស្រស់លើស្រែមុនពេលស្ទូង រឺក្រោយពេលច្រូតនោះរឹតតែប្រសើរថែមទៀត។ អាចដាក់ជីធម្មជាតិបំប៉ននៅតាមចន្លោះ គុម្ពសន្ទូងក៏បាន ។

## កំណត់សំគាល់

- ដំណាំស្រូវមិនមែនជារុក្ខជាតិទឹកទេ ប៉ុន្តែវាអាចធន់ទ្រាំដោយអាចដុះលូតលាស់ក្នុងទឹកបាន។ ប្រសិនបើគេដាំស្រូវក្នុងស្រែដែលមានសំណើមគ្រប់គ្រាន់ដោយមិនលិចទឹកនោះ វាអាចដុះលូតលាស់ និងបែកគុម្ពល្អជាងក្នុងស្រែ ដែលលិចទឹកទៅទៀត ។
- ដំណាំស្រូវ នឹងកាត់បន្ថយសក្តានុពលធម្មជាតិក្នុងការបែកគុម្ព បើសិនយើងស្ទូងសំណាបអាយុលើសពី ១៥ ថ្ងៃ។
- ដំណាំស្រូវនឹងមានសក្តានុពលបែកគុម្ពខ្ពស់ប្រសិនបើយើងកាត់បន្ថយភាពរន្ធត់របស់វាដូចជាការដកសំណាបដោយបោក នឹង ជើងខ្លាំងៗ រួចយកវាទៅចងរឹតជាកណ្តាប់ ... ។ល។
- ប្រសិនបើដំណាំស្រូវដុះតែឯង នោះវានឹងលូតលាស់ហើយបែកគុម្ពតាមសក្តានុពលធម្មជាតិរបស់វា ។
- ដំណាំស្រូវនឹងលូតលាស់បានល្អ ប្រសិនបើដីធូរមានខ្យល់ចេញចូល និងមានជីជាតិគ្រប់គ្រាន់ ។



CIRD
វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជនបទកម្ពុជា (សៀដ)
ផ្ទះលេខ ៣៥ ផ្លូវ ៤១០ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រ ២៥៤៣
Tel / Fax: +855 23 726 728; E-mail: cird@cird.org.kh; Website : www.cird.org.kh

CIRD
MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN
aecid

# បច្ចេកទេសធ្វើស្រែ ឱ្យបានទិន្នផលខ្ពស់

បច្ចេកទេសដែលលើកយកមកបង្ហាញនៅក្នុងខិតប័ណ្ណនេះ ត្រូវបានគេស្គាល់ជាទូទៅថាជាប្រពន្ធ័ប្រពលវប្បកម្ម ដំណាំស្រូវតាមគោលការណ៏ធម្មជាតិ ដែលហៅកាត់ថា "ប.វ.ស " ដោយលោក ហង់រី ដឺឡាឡូនៀ បានសង្កេតឃើញតាមរយៈការប្រមូលបទពិសោធន៏ពីកសិករនិងធ្វើការផ្សព្វផ្សាយតំបូងនៅក្នុងប្រទេសម៉ាដាហ្គាស្កា នាទសវត្សរ ឆ្នាំ ៨០ ។






# គោលការណ៍បច្ចេកទេសសំខាន់ៗដែលត្រូវអនុវត្ត

## ១. ពង្រាបផ្ទៃដីស្រែឲ្យបានរាបស្មើ

គឺដើម្បីឱ្យការផ្គត់ផ្គង់ទឹក និង ជីជាតិបានស្មើដល់គ្រប់គុម្ពស្រូវនៅក្នុងស្រែ។



## ២.ជ្រើសរើសយកគ្រាប់ពូជដែលពេញល្អយកទៅសាប

គ្រាប់ពូជដែលពេញល្អធ្វើឱ្យសំណាបថ្លោស និងឆាប់លូតលាស់ក្រោយពេលស្ទូង។ ដើម្បីជ្រើសរើសយកគ្រាប់ពូជស្រូវដែលពេញល្អ ត្រូវធ្វើតាមវិធីដូចខាងក្រោម:

- ដាក់ពងមាន់ រឺពងទាចូលក្នុងធុងទឹក រួចចាក់អំបិលបន្តិចចូលទៅក្នុងធុងនោះ បន្ទាប់មកកូរវាឱ្យរលាយអស់។ បើស៊ុតមិនទាន់អណ្តែកឡើងទេ យើងត្រូវចាក់អំបិលបន្ថែមរហូតទាល់តែស៊ុតនោះអណ្តែតឡើងលើផ្ទៃទឹក។
- ចាក់គ្រាប់ពូជចូលឱ្យបានពាក់កណ្តាលធុងរួចកូរឱ្យសព្វ
- កៀរយកគ្រាប់ស្រូវណាដែលអណ្តែតចេញរួចស្រង់គ្រាប់ដែលលិចទឹកយកទៅលាងសំអាត មុននឹងដាក់ត្រាំសំរាប់យកទៅសាប។

## ៣.ធ្វើថ្នាលសំណាបឲ្យខ្ពស់ផុតពីទឹក រឺធ្វើថ្នាលគោក

ត្រូវធ្វើថ្នាលសំណាបដូចគ្នានឹងការធ្វើរងសំរាប់សាបស្ពៃជាការល្អ ត្រូវប្រើជីកំប៉ុស ឬជីលាមកសត្វដែលពុកផុយល្អនៅលើថ្នាលប្រមាណពី ៣-៤ គ.ក្រ លើផ្ទៃដី ១ម៉ែត្រការ៉េ។ ត្រូវសាបគ្រាប់ពូជស្រូវឱ្យឃ្លាតរង្វើលពីគ្នា។ ជាមធ្យមគេប្រើពូជត្រឹមតែ ១៥គ.ក្រ ប៉ុណ្ណោះសំរាប់ស្ទូងលើផ្ទៃដីមួយហិកតា។

## ៤.ស្ទូងសំណាបខ្ចី និង ដកតែសំណាបដែលថ្លោសយកទៅស្ទូង

គួរស្ទូងសំណាបដែលមានអាយុត្រឹមពី ១៥ ទៅ ២០ ថ្ងៃ ព្រោះសំណាបមានពេលវេលាច្រើនសំរាប់បែកគុម្ព។ ត្រូវដក យកតែសំណាបដែលថ្លោសល្អទៅស្ទូង ព្រោះវាអាចដុះលូតលាស់ល្អ និងឆាប់បែកគុម្ព។



## ៥. ស្ទូងដោយចាប់សំណាបស្តើងៗ

យកល្អគួរស្ទូងត្រឹមពី ១ ទៅ ២ ដើម ក្នុង ១ គុម្ព ព្រោះមិនធ្វើឱ្យស្រូវចង្អៀតគ្នាពេក និងឆាប់បែកគុម្ព។ ត្រូវស្ទូងថ្នមៗរាក់ៗ និងដកភ្លាមស្ទូងភ្លាម។



## ៦. ស្ទូងរង្វើល និងត្រង់ជួរ

យកល្អគួរស្ទូងឱ្យរង្វើលជាងធម្មតាបន្តិច និងស្ទូងជាជួរចន្លោះពីគុម្ពមួយទៅគុម្ពមួយស្មើរគ្នា ដើម្បីឱ្យស្រូវអាចទទួលបានសារធាតុចិញ្ចឹមស្មើរគ្នា បែកគុម្ពបានល្អ និងងាយស្រួលដកស្មៅ។ ចន្លោះគុម្ពពី ២០-៣០ សង់ទីម៉ែត្រ និងចន្លោះជួរអាចពី ៣០ ទៅ ៤០ សង់ទីម៉ែត្រ អាស្រ័យទៅតាមពូជ ប្រភេទដី និងជីជាតិរបស់ដី។

## ៧. ការសំអាតស្មៅចង្រៃ

ត្រូវសំអាតស្មៅឱ្យបានពី ៣-៤ដង ជាពិសេសនៅពេលសន្ទូងកំពុងបែកគុម្ព។ ការដកស្មៅជួយឱ្យខ្យល់ចេញចូលក្នុងដីបានល្អ និងធ្វើឱ្យឫសស្រូវលូតលាស់បានច្រើន។ លើសពីនេះទៀត វានឹងបំបាត់ការប្រជែងដណ្តើមជីជាតិរបស់ស្មៅជាមួយស្រូវផងដែរ។